**<<INSERT SCHOOL LOGO / INFORMATION HERE – GRADE 7 AND UP – WEB-BASED SURVEY>>**

**<<DATE>>**

គោរពជូនមាតាបិតាៈ

ក្នុងក្នុងឆមាស នៃ**រដូវធ្លាក់ទឹកកក** សិស្សថ្នាក់ទី <<**INSERT GRADES**>> នៅក្នុងសាលារបស់យើងនឹងចូលរួមធ្វើ ការស្ទង់មតិតាមអ៊ិនធឺណិត**ដោយអនាមិក**មួយ។ ការស្ទង់មតិ**ដោយអនាមិក** គឺនៅពេលសិស្សមិនផ្តល់ឈ្មោះរបស់ពួកគេដល់ យើង។ សិស្សានុសិស្សនៅរដ្ឋ Maine ប្រហែលជា 96,000 ត្រូវបានស្នើអោយធ្វើការស្ទង់មតិ។ ការស្ទង់មតិ នឹងចំណាយពេលប្រហែលជាពេលយើងរៀនមួយមេរៀន។ ខាងក្រោមគឺជាចម្លើយចំពោះសំណួរមួយ ចំនួន ដែលអ្នកអាចនឹងមានអំពីការស្ទង់មតិនេះ។

**<u>តើសំណួរអ្វីខ្លះដែលត្រូវលើកយកមកសួរក្នុងការស្ទង់មតិនេះ?</u>**

ការស្ទង់មតិសួរសំណួរអំពីសុខភាព និងសុខភាពទាក់ទងនឹងការប្រព្រឹត្តនានា។ ប្រធានបទមួយចំនួនដែល រួមបញ្ចូលមានដូចជាៈ

- ជម្ងឺហឺត
- អ្វីដែលសិស្សានុស្សបរិភោគ
- សកម្មភាពរាងកាយ
- ការជក់បារី
- ការផឹកស្រា
- និងគ្រឿងញៀនផ្សេងៗ
- ការបង្ការការរលាកដោយកំដៅថ្ងៃ
- ពិការភាព
- ការវាយតប់គ្នា និងការគំរាមកំហែង
- ភេទ
- ជំងឺធ្លាក់ទឹកចិត្តនិងការធ្វើអត្តឃាត
- ការលេងហ្គេម

វាក៏បានសួរអំពីកត្តានៅសាលា នៅក្នុងសហគមន៍របស់ពួកគេ នៅក្នុងគ្រួសារ និងក្នុងចំណោមមិត្ត ភក្តិរបស់ពួកគេផងដែរ ដែលអាចគាំទ្រ ឬគំរាមកំហែងដល់ជម្រើសសុខភាពល្អរបស់សិស្ស។ សំណួរ ទាំងនេះរួមមាន ប្រធានបទដូចជាៈ

- ថាតើសិស្សអាចនឹងត្រូវចាប់ខ្លួនប្រសិនបើពួកគេកំពុងប្រើប្រាស់ថ្នាំជក់ ឬថ្នាំញៀន
- ថាតើមិត្តភក្តិរបស់ពួកគេប្រើថ្នាំញៀន
- ថាតើពួកគេចូលរួមក្នុងក្លឹប ឬសេវាកម្មរបស់សហគមន៍
- ការគាំទ្រ និងបទបញ្ញត្តិអ្វីដែលពួកគេមាននៅសាលា និងនៅផ្ទះ

សំណួរខុសៗគ្នាតាមកម្រិតថ្នាក់របស់សិស្ស។ ពួកគេគឺសមស្របទៅនឹងអាយុជាសិស្ស។ អ្នកអាច មើលនូវសំណួរដែលនឹងត្រូវបានសួរទាំងដោយការទាក់ទងសាលារបស់កូនលោកអ្នក ឬដោយទស្សនាគេហទំព័រ MIYHS ។

**<u>តើការស្ទង់មតិបានមកពីណា?</u>**

ការស្ទង់មតិនេះគឺជាកិច្ចខំប្រឹងប្រែងរួមគ្នារវាងក្រសួងសេវាកម្មសុខភាព និងធនធានមនុស្ស (DHHS) នៅរដ្ឋ Maine និងក្រសួងអប់រំ (DOE)នៅរដ្ឋ Maine។ ការស្ទង់មតិនេះនឹងត្រូវបានប្រើប្រាស់ដើម្បីសិក្សា បន្ថែមអំពីសិស្សានុសិស្សទាំងអស់នៅរដ្ឋ Maine។ លទ្ធផលប្រហែលជាត្រូវបានប្រើប្រាស់ក្នុងការទទួល បានមូលនិធិ ដើម្បីជួយសម្រេចចិត្តថាតើកម្មវិធីអ្វីដើម្បីផ្តល់ជូន ឬដើម្បីវិនិច្ឆ័យថាតើកិច្ចខំប្រឹងប្រែង បច្ចុប្បន្នកំពុងដំណើរការបានល្អប៉ុណ្ណា។

**<u>តើហេតុអ្វីបានជាកូនរបស់ខ្ញុំគួរតែធ្វើការស្ទង់មតិនេះ?</u>**

លទ្ធផលនៃការស្ទង់មតិនេះនឹងជួយដល់កម្មវិធីរបស់រដ្ឋ ក្រុមសហគមន៍ និងការផ្តល់សេវារបស់សាលា បានល្អប្រសើរដល់កូនរបស់អ្នក។

*<u>តើខ្ញុំអាចប្រាកដទេថាការស្ទង់មតិនេះនឹងមិនមានផលអាក្រក់ដល់កូនរបស់ខ្ញុំ?</u>*

- **កូនរបស់អ្នកមានសិទ្ធិធ្វើឬមិនការស្ទង់មតិដោយសេរី។** ប្រសិនបើកូនរបស់អ្នកជ្រើសរើសមិនធ្វើការស្ទង់មតិ នោះគ្រូបង្រៀននឹងផ្តល់អោយកូនរបស់អ្នកធ្វើនៅពេលណាមួយទៀតកំឡុងពេលរៀន។
- សិស្សមួយចំនួនអាចនឹងជួបនឹងសំណួរខ្លះៗដែលរសើប។ ពួកគេអាចនឹងមានអារម្មណ៍មិនស្ងួស្រួល ក្នុងការឆ្លើយសំណួរទាំងនោះ។
- សិស្សរាល់គ្នាអាចរំលងសំណួរណាមួយដែលគេមិនចង់ឆ្លើយ។
- ប្រសិនបើកូនរបស់អ្នកមិនសប្បាយចិត្តកំឡុងពេល ឬបន្ទាប់ពីការស្ទង់មតិ នោះបុគ្គលិកសាលានឹងចាំ ធ្វើការពិភាក្សា និងផ្តល់ជូននូវជំនួយផ្សេងៗ។
- មិនមានការពិន័យទេសម្រាប់ការមិនបានធ្វើការស្ទង់មតិ ឬមិនបានឆ្លើយរាល់សំណួរទាំងអស់។
- **ការស្ទង់មតិនេះត្រូវបានរៀបចំឡើងដើម្បីការពារឯកជនភាពកូនរបស់លោកអ្នក។**
- ចម្លើយទាំងឡាយដែលបានពីសិស្សណាម្នាក់មិនត្រូវបានរាយការដោយបុគ្គលទេ។ មិនមានសិស្សណាត្រូវបានគេ បញ្ចេញឈ្មោះនៅក្នុងរបាយការណ៍ណាមួយទេ។
- មិនមានពត៌មានណាដែលភ្ជាប់កូនរបស់អ្នកទៅនឹងចម្លើយនៃការស្ទង់មតិផ្ទាល់ខ្លួនរបស់គេនឹងត្រូវបាន រក្សាទុក។
- ចំពោះការអង្កេតតាមអ៊ិនធឺណិត គឺយើងខ្ញុំនឹងមិនចាប់យកព័ត៌មានអំពី អាសយដ្ឋាន IP ឬអាសយដ្ឋានអ៊ីម៉េលរបស់ម៉ាស៊ីនដែលកូនអ្នកប្រើឡើយ នេះគឺ ដើម្បីជាការបញ្ជាក់ថា អត្តសញ្ញាណកូនរបស់អ្នក នឹងស្ថិតនៅជាអនាមិក ហើយទិន្នន័យដែលទទួលបានពីកូនអ្នក នឹងត្រូវ

រក្សាទុកក្នុងម៉ាស៊ីនមេដែលមានសន្តិសុខល្អ ។

**<u>តើមានអ្វីកើតឡើងប្រសិនបើខ្ញុំមានសំណួរបន្ថែមអំពីការស្ទង់មតិ?</u>**

- ប្រសិនបើលោកអ្នកចង់ឃើញការស្ទង់មតិ អ្នកអាចហៅទូរស័ព្ទទៅកាន់ការិយាល័យសាលាដើម្បីកំណត់ពេលប្រជុំ មុនពេលកាលបរិច្ឆេទស្ទង់មតិ ឬចូលទស្សនាគេហទំព័រ៖ www.maine.gov/MIYHS
- ប្រសិនបើលោកអ្នកមានសំណួរអំពីការស្ទង់មតិនេះ សូមទាក់ទងជាមួយ ៖

    Korey Pow (មជ្ឈមណ្ឌលគ្រប់គ្រងជំងឺឆ្លង- CDC ប្រចាំរដ្ឋមេន) តាមទូរស័ព្ទលេខ (207)-287-5084 ឬតាមអ៊ីម៉េល korey.pow@maine.gov ឬ

    Jean Zimmerman (នាយកដ្ឋានសិក្សាធិកា- DOE ប្រចាំរដ្ឋមេន) តាមទូរស័ព្ទលេខ (207) 215-6841 ឬតាមអ៊ីម៉េល jean.zimmerman@maine.gov
- ប្រសិនបើអ្នកមានសំណួរអំពីសិទ្ធិរបស់លោកអ្នក ឬសិទ្ធិកូនរបស់លោកអ្នកដែលជាផ្នែកនៃការស្ទង់ មតិនេះ អ្នកអាចហៅទូរស័ព្ទទៅកាន់មន្ត្រីរដ្ឋបាលការពារសិទ្ធិមនុស្ស តាមរយៈលេខ (207) 228-8434 និង/ឬ តាមអ៊ីម៉ែល usmorio@maine.edu ។ ក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន (IRB) នៅសាកលវិទ្យាល័យ Southern Maine មានអនុម័តយកការប្រើប្រាស់ការស្ទង់មតិនេះ។ IRB ទទួលខុសត្រូវក្នុងការការពារ សិទ្ធិ និងសុខុមាលភាពរបស់អ្នកចូលរួមក្នុងការស្ទង់មតិ។

ប្រសិនបើលោកអ្នកមិនចង់អោយកូនរបស់លោកអ្នកធ្វើការស្ទង់មតិទេ សូមទាក់ទងមកកាន់ការិយាល័យសាលា។ អ្នកក៏អាចបដិសេធមិនអោយកូនរបស់អ្នកថ្លឹងទម្ងន់ និងវាស់កម្ពស់បានដែរ។ ប្រសិនបើយើងមិនទទួលដំណឹងពីលោកអ្នកទេ នោះយើងនឹងសន្មតថាអ្នកយល់ព្រមអោយកូនរបស់លោកអ្នកចូលរួម ហើយ។ កូនរបស់លោកអ្នកក៏អាចសម្រេចចិត្តមិនធ្វើការស្ទង់មតិនៅថ្ងៃដែលវាប្រព្រឹត្តធ្វើដែរ។

ដោយក្តីស្មោះស្ម័គ្រ

**<<PRINCIPAL'S NAME>>**
នាយកសាលា

IRB 15-07-562
Approved by USM IRB
May 6, 2021 – May 5, 2022